**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:...០១...សរ..**

# សារាចរ
# ស្ដីពី
# វិធានការសម្រាប់ការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល យោធិន នគរបាលជាតិ មន្ត្រីជាប់កិច្ចសន្យា និងបុគ្គលិកអណ្ដែត ក្នុងឆ្នាំ២០១៥

ក្នុងឆ្នាំ២០១៤និងដើមឆ្នាំ២០១៥នេះ រាជរដ្ឋាភិបាលបានដាក់ចេញជាបន្តបន្ទាប់នូវគោលការណ៍និងវិធានការនៃការកែទម្រង់ ដើម្បីលើកកម្ពស់អភិបាលកិច្ច ពង្រឹងប្រសិទ្ធភាពនៃការផ្ដល់សេវាសាធារណៈ និងការលើកកម្ពស់ជីវភាពរស់នៅរបស់មន្ត្រីរាជការ។ ក្នុងក្របខណ្ឌនៃការងារកែទម្រង់ប្រព័ន្ធបៀវត្សមន្ត្រីរាជការឱ្យមានសង្គតិភាព សមធម៌ ផលិតភាព ផ្អែកលើលទ្ធភាពទ្រទ្រង់បាននៃថវិកាជាតិ រាជរដ្ឋាភិបាលបានធ្វើការកែលម្អគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋដើម្បីធានាឱ្យកាន់តែប្រសើរការវិវត្តអាជីពរបស់មន្ត្រីរាជការស៊ីវិល បានធ្វើសមាហរណកម្មមន្ត្រីរាជការរួចរាល់ទៅក្នុងរចនាសម្ព័ន្ធមុខងារសាធារណៈថ្មី បានធ្វើនិយ័តកម្មថ្នាក់និងឋានន្តរស័ក្តិជូនមន្ត្រីរាជការ ធានាបើកផ្ដល់បៀវត្សប្រចាំខែជូនមន្ត្រីរាជការបានទាន់ពេលវេលា រៀបចំការបើកផ្ដល់បៀវត្សតាមប្រព័ន្ធធនាគារ ដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិល បង្កើនប្រាក់ហូបប្រចាំថ្ងៃជូនយោធិននិងនគរបាលជាតិ កែសម្រួលប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល កែសម្រួលបៀវត្សមូលដ្ឋាននិងការបើកផ្ដល់បៀវត្សជូនយោធិននៃកងយោធពលខេមរៈភូមិន្ទនិងនគរបាលជាតិ ព្រមជាមួយនឹងការរៀបចំនិងដាក់ឱ្យអនុវត្តវិធានការគាំទ្រផ្សេងទៀតជាច្រើន។

ដើម្បីធានាការអនុវត្តកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាលឱ្យប្រព្រឹត្តទៅដោយរលូននិងទទួលបានជោគជ័យស្របតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ពិសេសដើម្បីគាំទ្រការរៀបចំប្រព័ន្ធបៀវត្សថ្មីសម្រាប់ឆ្នាំ២០១៥ និងវិធានការសម្រាប់ការបង្កើនបៀវត្សជូនមន្ត្រីរាជការ រាជរដ្ឋាភិបាលសូមធ្វើការណែនាំដល់ក្រសួង ស្ថាប័ន ដូចខាងក្រោម៖

១- ក្នុងឆ្នាំ២០១៥ ការជ្រើសរើសក្របខណ្ឌថ្មីមន្ត្រីរាជការស៊ីវិលនៃគ្រប់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ យោធិន និងនគរបាលជាតិ ត្រូវបានអនុញ្ញាតជ្រើសរើសស្មើនឹងចំនួនមន្ត្រីរាជការដែលបាត់បង់ពីក្របខណ្ឌដោយហេតុចូលនិវត្តន៍ លាឈប់ បញ្ឈប់ពីការងារ បាត់បង់សម្បទាវិជ្ជាជីវៈ ឬមរណភាព។

២- ក្រសួង ស្ថាប័ន និងអង្គភាពដែលបង្កើតថ្មី ត្រូវប្រើប្រាស់មន្ត្រីរាជការដែលមានស្រាប់ឱ្យអស់លទ្ធភាព ហើយការជ្រើសរើសក្របខណ្ឌថ្មី ត្រូវមានលក្ខណៈរឹតត្បិតបំផុត និង ស្ថិតក្នុងក្របខណ្ឌនៃច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥។

៣- ជៀសវាងការរៀបចំបង្កើត ឬ រៀបចំរចនាសម្ព័ន្ធថ្មីនៅតាមក្រសួង ស្ថាប័ន ឬ នៅតាមមន្ទីរជុំវិញរាជធានី ខេត្តដែលជាហេតុនាំឱ្យមានតម្រូវការជ្រើសរើសមន្ត្រីថ្មី។ ក្នុងករណីចាំបាច់ រចនាសម្ព័ន្ធថ្មីអាចត្រូវបានកែសម្រួលឬរៀបចំថ្មី ប៉ុន្តែមិនត្រូវមានការជ្រើសរើសក្របខណ្ឌថ្មីបន្ថែមទៀតឡើយ។

៤- ដើម្បីផ្តល់លក្ខណៈងាយស្រួលដល់ការដាក់ឱ្យដំណើរការសន្ទស្សន៍បៀវត្សនិងប្រាក់បំណាច់មុខងារថ្មី ការប្រឡងផ្ទៃក្នុងផ្លាស់ប្តូរប្រភេទក្របខណ្ឌ និងការដំឡើងឋានន្តរស័ក្តិឬថ្នាក់របស់មន្ត្រីរាជការស៊ីវិលនៃក្រសួង ស្ថាប័ននៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ យោធិន និងនគរបាលជាតិ មិនត្រូវអនុវត្តឡើយក្នុងឆ្នាំ២០១៥។

៥- ការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យា និង បុគ្គលិកអណ្តែត ត្រូវបានអនុញ្ញាតជ្រើសរើសស្របតាមចំនួនដែលទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាល។ ក្នុងករណីចាំបាច់ ការជ្រើសរើសថ្មីបន្ថែមត្រូវស្ថិតក្រោមការត្រួតពិនិត្យហ្មត់ចត់ពីក្រសួងមុខងារសាធារណៈនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

៦- គ្រប់ក្រសួង ស្ថាប័ន ត្រូវសហការជាមួយក្រសួងមុខងារសាធារណៈ ដើម្បីពិនិត្យឡើងវិញស្ថានភាពនៃការប្រើប្រាស់មន្ត្រីរាជការស៊ីវិលនៅតាមក្រសួង ស្ថាប័ន ក្នុងគោលដៅធានាការជ្រើសរើស ការពង្រាយមន្ត្រីរាជការ ការផ្លាស់ប្តូរការងារ និងការប្រើប្រាស់ធនធានមនុស្សក្នុងមុខងារសាធារណៈឱ្យស្របតាមសេចក្តីត្រូវការពិតប្រាកដនៃការងារ ។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន ត្រូវផ្សព្វផ្សាយនិងអនុវត្តក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យមានប្រសិទ្ធភាពនិងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិនា ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ